**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Jan-2012, 09:32
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ការជំទាស់របស់លោក អៀង សារី ចំពោះការទទួលយកឯកសារមួយចំនួនពីការិយាល័យ សហព្រះរាជអាជ្ញាសម្រាប់សវនាការបួនវគ្គដំបូង

---

| ដាក់ដោយ÷ | ដាក់ជូនចំពោះ÷ | ដាក់ជូនចំពោះ÷ |
|---|---|---|
| **មេធាវីការពារក្តី÷** | **ចៅក្រមអង្គជំនុំជម្រះសាលាដំបូង÷** | **សហព្រះរាជអាជ្ញា÷** |
| អាង ឧត្តម | ចៅក្រម **និល ណុន** | ជា លាង |
| Michael G. KARNAVAS | ចៅក្រម **យូរ ឧត្តរា** | Andrew CAYLEY |
| | ចៅក្រម **យ៉ា សុខន** | **មេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Silvia CARTWRIGHT | **ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបម្រុង **ធូ មុណី** | |
| | ចៅក្រមបម្រុង Claudia FENZ | |

លោក អៀង សារី តាមរយៈសហមេធាវីការពារក្តីរបស់លោក "មេធាវីការពារក្តី" ដោយអនុលោមតាមវិធាន ៨៤(១) និងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង សូមបង្ហាញការជំទាស់របស់ខ្លួននៅក្នុងឧបសម្ព័ន្ធដែលមានភ្ជាប់មកជាមួយនេះទាក់ទងនឹង ការទទួលយកឯកសារមួយចំនួនពីការិយាល័យសហព្រះរាជអាជ្ញាសម្រាប់សវនាការបួនវគ្គដំបូង ទៅតាមការបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងអនុស្សរណៈរបស់ខ្លួនចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១[១]។ ឧបសម្ព័ន្ធទាំងឡាយដែលភ្ជាប់មកជាមួយគឺដូចគ្នានឹងឧបសម្ព័ន្ធនានាដែលរៀបរាប់ពីឯកសារទាំងឡាយដែលបានស្នើឡើងដោយ កសព ដោយមានបន្ថែមមួយគូឡោនទៀតនៅខាងស្តាំសម្រាប់ជាការជំទាស់របស់មេធាវីការពារក្តី ដើម្បីងាយស្រួលធ្វើការចង្អុលបង្ហាញ។ ឧបសម្ព័ន្ធ ៧ និង ២១ មិនត្រូវបានដាក់ភ្ជាប់មកជាមួយនៅក្នុងការជំទាស់របស់មេធាវីការពារក្តីទេ ព្រោះថាឧបសម្ព័ន្ធ ៧ គឺរួមបញ្ចូលឯកសារនានាដែល កសព បានស្នើសម្រាប់ការជំនុំជម្រះក្តីវគ្គទីមួយ ដែលត្រូវបានមេធាវីការពារក្តីបានជំទាស់រួចរាល់ហើយ ទៅនឹងការទទួលយកឯកសារមួយចំនួននៅក្នុងឧសម្ព័ន្ធនេះ។ ឧបសម្ព័ន្ធ ២១ គឺជាបញ្ជីសម្រាប់ឯកសារថ្មីៗ ដែលឯកសារថ្មីៗទាំងនោះត្រូវបានបញ្ចូលទៅក្នុងឧបសម្ព័ន្ធផ្សេងៗទៀតរបស់ កសព។ មេធាវីការពារក្តីសូមដាក់ការជំទាស់ទាំងនេះ បើទោះជាខ្លួនបានគោរពតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការជំទាស់នឹងឯកសារមួយចំនួនសម្រាប់សវនាការដំណាក់កាលដំបូងដែលបានចែងថា ភាគីទាំងអស់អាចជំទាស់ទៅនឹងឯកសារនានាទៅតាមប្រភេទនៃឯកសារទាំងនោះ[២]។ មេធាវីការពារក្តីសូមដាក់ការជំទាស់ទាំងនេះដើម្បីជួយដល់អង្គជំនុំជម្រះ

---

[១] "អង្គជំនុំជម្រះសាលាដំបូងបង្គាប់បន្ថែមឲ្យភាគីបញ្ជាក់យ៉ាងយូរត្រឹមថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២ អំពីថាតើភាគីចង់ជំទាស់ទៅនឹងឯកសារនៅសេសសល់ណាខ្លះរបស់ភាគីបដិបក្ខដែលបានស្នើឲ្យមានការទទួលយក ទាក់ទងនឹងសវនាការបួនវគ្គដំបូងដែរឬទេ និងផ្តល់មូលដ្ឋាននៃការជំទាស់របស់ខ្លួនផង"។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5, ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E131/1, ទំព័រទី ២។

[២] *សូមមើលឯកសារខាងលើផងដែរ។ សូមមើលផងដែរ* ការជំទាស់របស់លោក អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារជាក់លាក់មួយចំនួន ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E114; សំណើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មក្នុងពេលជំនុំជម្រះ ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E33; សារណារបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់សម្ភារៈទាំងអស់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូល ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E59; ចម្លើយតបរបស់ លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឲ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E96/3។

សាលាដំបូង ក្នុងការសម្រេចលើភាពអាចទទួលយកបាននៃឯកសារជាក់លាក់មួយចំនួនសម្រាប់ធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/១ និងដើម្បីបង្កើនភាពច្បាស់លាស់ និងសច្ចភាពទាក់ទងនឹងជំហររបស់មេធាវីការពារក្តីចំពោះឯកសារនីមួយៗ។ ការជំទាស់ទាំងនេះត្រូវបានដាក់ជូនក្នុងលក្ខខណ្ឌថា មេធាវីការពារក្តីមិនអាចវាយតម្លៃយថាភាពនៃឯកសារទាំងនេះ។ ដូច្នេះ មេធាវីការពារក្តីសូមជំទាស់ទៅនឹងការទទួលយកឯកសារណាមួយដែលបង្ហាញឲ្យឃើញថា គ្មានយថាភាព ឬក៏ត្រូវបានភាគីដែលព្យាយាមដាក់ឯកសារនោះ បង្ហាញថាមានយថាភាព។

**អាស្រ័យហេតុនេះ** ដោយផ្អែកលើមូលហេតុទាំងអស់ដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធដែលមានភ្ជាប់មកជាមួយនេះ មេធាវីការពារក្តីស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាច្រានចោលឯកសារនានាដែលមានក្នុងឧបសម្ព័ន្ធភ្ជាប់ជូនទាំងនេះ។

សូមដាក់ជូនការជំទាស់នេះដោយគោរពពី ៖

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីការពារក្តី អៀង សារី

ចុះហត្ថលេខា នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **៥** ខែ **មករា ឆ្នាំ ២០១២**